**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៥ អនក្រ

# សេចក្តីសម្រេច
# ស្តីពី
# ការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ច របស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការការងារចាំបាច់

## សម្រេច

**ប្រការ ១** : កំណត់របៀបរបបការងារ និងបែងចែកភារកិច្ច ជូននាយករដ្ឋមន្ត្រី, ឧបនាយករដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស សំដៅធានាការអនុវត្តច្បាប់ និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋ ដូចមានចែងក្នុងប្រការបន្តបន្ទាប់ខាងក្រោម ។

**ប្រការ ២** : នាយករដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំការងាររួម របស់គណៈរដ្ឋមន្ត្រី និងចាត់ចែងបញ្ហារាល់សកម្មភាព របស់រាជរដ្ឋាភិបាល លើគ្រប់វិស័យ។

**ប្រការ ៣** : ឧបនាយករដ្ឋមន្ត្រី ៖

១- សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជានាយករដ្ឋមន្ត្រីស្តីទី ពេលនាយករដ្ឋមន្ត្រីអវត្តមាន, ជួយនាយករដ្ឋមន្ត្រីលើការងារសន្តិសុខជាតិ ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការជួញដូរមនុស្ស, ដឹកនាំប្រតិបត្តិការទប់ស្កាត់ និងប្រឆាំងភេរវកម្ម, ដឹកនាំគណៈកម្មាធិការជាតិកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (គជវវ) និងការបំផ្លាញចោលអាវុធ ព្រមទាំងការងារភូមិ-ឃុំមានសុវត្ថិភាព និងការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី ។

២- សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកការងារការពារជាតិ, ទទួលសិទ្ធិពីនាយករដ្ឋមន្ត្រីក្នុងការបញ្ជាកងរាជអាវុធហត្ថលើផ្ទៃប្រទេស, ដឹកនាំកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងទទួលសិទ្ធិ ពីនាយករដ្ឋមន្ត្រី ក្នុងការបញ្ជាអង្គភាពពិសេសប្រឆាំង ភេរវកម្មក្នុងពេលនាយករដ្ឋមន្ត្រីអវត្តមាន និងការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី ។



www.pheakdeylaw.com

៣-ឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកផ្ដល់យោបល់ជូន នាយករដ្ឋមន្ត្រី អំពីក្របខ័ណ្ឌគោលនយោបាយក្រៅប្រទេស និងទទួលសិទ្ធិពីនាយករដ្ឋមន្ត្រី ក្នុងការពិនិត្យ និងសម្រេចលើការសំណើសុំកូន និងការសុំហេសញ្ជាតិ និងការងារពិសេសផ្សេងទៀត តាមការប្រគល់របស់នាយករដ្ឋមន្ត្រី ។

៤- លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រី លើការងាររដ្ឋធិការកិច្ច និងសវនកម្ម ព្រមទាំងជួយនាយករដ្ឋមន្ត្រីលើការងារសង្គម ។

៥- ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការ សម្របសម្រួលកិច្ចការសម្រាប់គណៈរដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី និងបណ្ដាឧបនាយករដ្ឋមន្ត្រី, ជួយនាយករដ្ឋមន្ត្រីក្នុងការងារតាមដានសម្របសម្រួលដំណើរការតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម, ដឹកនាំផ្ទាល់ក្រុមប្រឹក្សាអ្នកច្បាប់ ព្រមទាំងជួយនាយករដ្ឋមន្ត្រី ក្នុងការរៀបចំចម្លើយតបនឹងសំណួររបស់សមាជិករដ្ឋសភា ស្របតាមនីតិវិធីដូចមានចែងក្នុងមាត្រា ៩៦ នៃរដ្ឋធម្មនុញ្ញ, ដោះស្រាយការងារប្រចាំថ្ងៃជំនួសនាយករដ្ឋមន្ត្រី ទទួលសិទ្ធិពីនាយករដ្ឋមន្ត្រី ក្នុងការពិនិត្យ និងសម្រេចលើការងាររបស់ «ច្រកចេញ-ចូលតែមួយ» នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លើកលែងតែការងារដែលមានផលវិបាកភាពខ្ពស់ ដែលតម្រូវឲ្យសុំការណែនាំ ឬ ការសម្រេចពីនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រី លើការងារបង្ការ ទប់ស្កាត់ និងប្រឆាំងអំពើពុករលួយ ។

៦- ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ, ប្រធានគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ និងដឹកនាំសម្របសម្រួលវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងការងារពិសេសផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី ។

៧- ឯកឧត្តម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំផ្ទាល់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការងារពិសេសផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី ។

៨- ឯកឧត្តម **ទា្រក់ សុខុន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកការងារការបរទេស ការសម្របសម្រួលការបញ្ជូនកងកម្លាំងកម្ពុជាចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងការងារពិសេសផ្សេងទៀត តាមការប្រគល់របស់នាយករដ្ឋមន្ត្រី ។

៩- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកការងារលើវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ជាប្រធានគណៈកម្មការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម ហើយនិងជាប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងការងារពិសេសផ្សេងទៀត តាមការប្រគល់របស់នាយករដ្ឋមន្ត្រី ។

១០- ឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំផ្ទាល់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងការងារពិសេសផ្សេងទៀត តាមការប្រគល់របស់នាយករដ្ឋមន្ត្រី ។

**ប្រការ ៤** : នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ជាគណៈអចិន្ត្រៃយ៍នៃគណៈរដ្ឋមន្ត្រី ដែលត្រូវប្រជុំពិគ្រោះការងារ តាមការកោះអញ្ជើញរបស់នាយករដ្ឋមន្ត្រី ឬ នាយរដ្ឋមន្ត្រីស្ដីទី ។

**ប្រការ ៥** : ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកអនុវត្តការងារ ឬ បេសកកម្មផ្សេងទៀត ដែលនាយករដ្ឋមន្ត្រីប្រគល់ជូន ស្របតាមមាត្រា ៣០ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

**ប្រការ ៦** : ឧបនាយករដ្ឋមន្ត្រី ០១ រូបៗ មានទីប្រឹក្សា ០៤ រូប ក្នុងនោះ ០២ រូប មានឋានៈស្មើ រដ្ឋលេខាធិការ, ០២ រូប មានឋានៈស្មើ អនុរដ្ឋលេខាធិការ, និងជំនួយការ ០៥ រូប ក្នុងនោះ ០១ រូប មានឋានៈស្មើ អគ្គនាយក, ០២ រូប មានឋានៈស្មើ អគ្គនាយករង និង ០២ រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន។



www.pheakdeylaw.com

**ប្រការ ៧** : ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ៖

១- ឯកឧត្តម **ម៉ុល សារឿន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកការងារបញ្ជូនកងកម្លាំងកម្ពុជាចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ដោយរួមការងារជាមួយសម្តេចពិជ័យសេនា **ទៀ បាញ់** និងឯកឧត្តម **ច្រាក់ សុខុន** និងការងារស្វែងរកអដ្ឋិធាតុយុទ្ធជនអាមេរិក និងវៀតណាម និងការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី ។

២- ឯកឧត្តម **គន់ គីម** ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការអតីតយុទ្ធជន និងជនពិការ និងការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី ។

៣- ឯកឧត្តម **មាស សុភា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការមីន និងគ្រាប់មិនទាន់ផ្ទុះ និងការងារវិស្វកម្មកងយោធពលខេមរភូមិន្ទ និងការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី ។

៤- ឯកឧត្តម **ញឹម វណ្ណដា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកជាអនុប្រធានទី ១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

៥- ឯកឧត្តម **ខ្លឹម ម៉ិនឡៀង** ទេសរដ្ឋមន្ត្រីទទួលបន្ទុកដឹកនាំគណៈកម្មាធិការសិទ្ធិមនុស្សរបស់រាជរដ្ឋាភិបាល និងអង្គភាពប្រឆាំងអំពើពុករលួយ ។

៦- ឯកឧត្តម **មៀច ម៉ូលី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ ។

៧- ឯកឧត្តម **វ៉ា គឹមហុង** ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការព្រំដែន ។

៨- ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។

៩- ឯកឧត្តម **ជិន ម៉ិនសាន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកជាអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

១០- ឯកឧត្តម **ហូ សិទ្ធី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកជានាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី និងការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី ។

១១- ឯកឧត្តម **ឃុន ហាំង** ទេសរដ្ឋមន្ត្រីទទួលបន្ទុកជាអនុប្រធានប្រចាំការអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

១២- ឯកឧត្តម **លី ធុជ** ទេសរដ្ឋមន្ត្រីទទួលបន្ទុកជាប្រធានគណៈកម្មាធិការជាតិ ESCAP និងជាអនុប្រធានទី ១ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ។

១៣- ឯកឧត្តម **អូស្មាន ហាសាន់** ទេសរដ្ឋមន្ត្រីទទួលបន្ទុកជួយនាយករដ្ឋមន្ត្រី លើការងារចលនាមូស្លីម និងការងារផ្សេងទៀតតាមការប្រគល់របស់នាយករដ្ឋមន្ត្រី ។

**ប្រការ ៨** : ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ទទួលអនុវត្តបន្ថែមនូវការងារផ្សេងទៀត ដែលនាយករដ្ឋមន្ត្រីប្រគល់ជូន ។

**ប្រការ ៩** : ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ០១ រូបៗ មានជំនួយការ ០៥ រូប ក្នុងនោះ ០២ រូប មានឋានៈស្មើអគ្គនាយក, ០១ រូប មានឋានៈស្មើ អគ្គនាយករង និង ០២ រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន។

**ប្រការ ១០**: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១១**: នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ កញ្ញា ឆ្នាំ ២០១៨

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣, ៧ និង១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

៧/៣

www.pheakdeylaw.com